**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

**ក្រសួងព័ត៌មាន**

លេខ៖ ..................................... ព.ម.

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការរៀបចំវេទិកាប្រព័ន្ធផ្សព្វផ្សាយស្តីពីការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងការប្រកួតប្រជែងពានរង្វាន់ជ័យលាភីអ្នកផលិតមាតិកា ឆ្នាំ២០២៦

ក្រោមប្រធានបទ *«ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងការលើកកម្ពស់សុចរិតភាពព័ត៌មាន នៅក្នុងតំបន់មេគង្គ-ឡានឆាង»*

*(*Zero Fake News Media Forum and Awards 2026 )

ក្រសួងព័ត៌មាន សូមជម្រាបជូនដំណឹងដល់សាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ជ្រាបថា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៦ នេះ ក្រសួងព័ត៌មាន នឹងរៀបចំ «វេទិកាប្រព័ន្ធផ្សព្វផ្សាយស្តីពីការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងការប្រកួតប្រជែងពានរង្វាន់ជ័យលាភីអ្នកផលិតមាតិកា ឆ្នាំ២០២៦ ( Zero Fake News Media Forum and Awards 2026)» ក្រោមប្រធានបទ *«ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងការលើកកម្ពស់សុចរិតភាពព័ត៌មាននៅក្នុងតំបន់មេគង្គ-ឡានឆាង»* ក្រោមអធិបតីភាពរបស់ ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធនៅសណ្ឋាគារ Sun & Moon Riverside រាជធានីភ្នំពេញ ។

វេទិកានេះ រៀបចំឡើងក្រោមគម្រោង *«យុទ្ធនាការប្រឆាំងព័ត៌មានក្លែងក្លាយ ( Zero Fake News Campaign )៖ ការពង្រឹងកិច្ចខិតខំប្រឹងប្រែងប្រឆាំងព័ត៌មានមិនពិត បន្ទាប់ពីកម្មវិធីប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយសម្រាប់អ្នកសារព័ត៌មាន (ដំណាក់កាលទី២)»* ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។ កម្មវិធីនេះ នឹងមានការអញ្ជើញចូលរួមពីតំណាងស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា តំណាងស្ថានទូតនៃបណ្តាប្រទេសសមាជិកអាស៊ានប្រចាំកម្ពុជា មន្ត្រីនាំពាក្យក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត អ្នកសារព័ត៌មាន អ្នកផលិតមាតិកា អ្នកជំនាញផ្ទៀងផ្ទាត់ព័ត៌មាន តំណាងសង្គមស៊ីវិល ព្រមទាំងភគីន និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិមកពីបណ្តាប្រទេសជាសមាជិកមហាអនុតំបន់មេគង្គ រួមមាន កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា វៀតណាម និងថៃ សរុបប្រមាណ ៣០០នាក់។

វេទិកាពេញមួយថ្ងៃនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីហានិភ័យ និងផលប៉ះពាល់នៃព័ត៌មានក្លែងក្លាយ និងការចែកចាយព័ត៌មានដោយខ្វះការទទួលខុសត្រូវ។ វេទិកានេះក៏នឹងផ្តោតសំខាន់លើការចែករំលែកបទពិសោធល្អៗលើការផ្ទៀងផ្ទាត់ព័ត៌មានពិត (Fact-checking)

ការលើកកម្ពស់អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិងឌីជីថល ការឆ្លើយតបចំពោះការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ក្នុងការបង្កើតព័ត៌មានក្លែងក្លាយ និងការផ្សព្វផ្សាយព័ត៌មានអំឡុងពេលវិបត្តិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ក្នុងការទប់ស្កាត់ការសាយភាយព័ត៌មានមិនពិតឆ្លងដែន ស្របតាមទិសស្លោក *«ផ្ទៀងផ្ទាត់មុនចែករំលែក (Verify Before You Share)»* និង *«រួមគ្នាដើម្បីសុចរិតភាពព័ត៌មាន (Together for Information Integrity)»*។

ទន្ទឹមនឹងវេទិកាពិភាក្សា ក៏មានការរៀបចំពិធីប្រគល់ពានរង្វាន់ **«ជ័យលាភីអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាប្រឆាំងព័ត៌មានក្លែងក្លាយ** (Zero Fake News Media and Content Creator Awards)» ជូនដល់ម្ចាស់ជ័យលាភី ចំនួន ៥រូប ដែលបានចូលរួមផលិតមាតិកាប្រកបដោយភាពច្នៃប្រឌិត សីលធម៌វិជ្ជាជីវៈ និងមានឥទ្ធិពលវិជ្ជមានដល់សង្គម។

តាមការរំពឹងទុក វេទិកានេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងបណ្តាញអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាដែលមានទំនួលខុសត្រូវខ្ពស់ លើកកម្ពស់ទំនុកចិត្តសាធារណៈលើប្រភពព័ត៌មានច្បាស់ការណ៍ ព្រមទាំងពង្រឹងភាពធន់របស់សង្គមជាតិ និងតំបន់មេគង្គ-ឡានឆាងទាំងមូលក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយប្រកបដោយប្រសិទ្ធភាព ជាពិសេសវេទិកានេះ នឹងជួយពង្រឹងតួនាទីដ៏សំខាន់របស់កម្ពុជា ក្នុងការចូលរួមជាមួយប្រទេសជាសមាជិកមហាអនុតំបន់មេគង្គ ក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយឆ្លងដែន ដែលបាននិងកំពុងចរាចរយ៉ាងឆាប់រហ័សនៅក្នុងតំបន់៕

ថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកញ្ញា ឆ្នាំ២០២៦

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងព័ត៌មាន